**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យសមុទ្រលើកទី៩ ជុំទី៣ ឆ្នាំ២០២០ នៅខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់ពិធីបុណ្យសមុទ្រ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យសមុទ្រលើកទី៩ ជុំទី៣ ដែលនឹងប្រព្រឹត្តទៅក្នុងកំឡុង ខែធ្នូ ឆ្នាំ២០២០ នៅខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **គួច ចំរើន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ជា ម៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- ឯកឧត្តម **ឈួន ដារ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៧- ឯកឧត្តមវេជ្ជបណ្ឌិត **សាន់ សាម់អ៊ី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨- ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- ឯកឧត្តម **សំ សិរីរ័ត្ន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តម **ហាស់ សារ៉េត** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ | សមាជិក |
| ១១- ឯកឧត្តម **សៅ សុភាព** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២- ឯកឧត្តម **ម៉ូ វេតនា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣- ឯកឧត្តម **ណែត តឿត** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ១៤- ឧត្តមសេនីយ៍ឯក **យឹម លាង** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៥- ឧត្តមសេនីយ៍ឯក **គឿន សុភក្ត្រា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៦- ឧត្តមសេនីយ៍ឯក **ម៉ន សាម៉ុន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧- លោក **យស់ សុខេមរៈ** | ប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- លោក **ទុំ ណូ** | ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ | សមាជិក។ |

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទី និងភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំពិធីបុណ្យសមុទ្រលើកទី៩ ជុំទី៣ នៅខេត្តព្រះសីហនុ ដែលនឹងប្រព្រឹត្តទៅក្នុងកំឡុង ខែធ្នូ ឆ្នាំ២០២០។

**ប្រការ៣.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាសេនាធិការ និងអនុគណៈកម្មការអន្តរក្រសួងមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើថវិការបស់ក្រសួងទេសចរណ៍ និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភដល់ដំណើរការរៀបចំពិធីបុណ្យសមុទ្រឆ្នាំ២០២០។

**ប្រការ៥.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអ្នកជំនាញពាក់ព័ន្ធផ្សេងៗទៀត ចូលរួមកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង។

**ប្រការ៦.-**

គណៈកម្មការអន្តរក្រសួងនេះ នឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ